៩	លោក ធុយ សុខន និង នាង លឹម ចន្ថា	៦៧៦ ម^២
១០	លោក សេង ចិន (តំណាងឱ្យ ឡោ ខាន់)	៥៣០ ម^២
១១	លោក យ៉ិន សុវណ្ណ (តំណាងឱ្យ ឡោ ផុន)	១.១១៦ ម^២
១២	លោក ម៉េត សុភា និង នាង ហ៊ីង សារ៉េត	៨២៦ ម^២
១៣	លោក ហ៊ីង តុលា (តំណាងឱ្យ ហ៊ីង ធន និងនាង យង់ សារី)	១.៨១៨ ម^២
១៤	លោក អ៊ុក សារ៉ែន និងនាង អាត វណ្ណា	២.៩៧០ ម^២
១៥	លោក រូ រិន	៥៩១ ម^២
សរុប		**១០.៥០៣ ម^២**

ឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ២២៨ អនក្រ.បក **ចុះថ្ងៃទី** ៤ **ខែ** សីហា **ឆ្នាំ២០២៣**
ស្តីពីការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ

ល.រ	អាប់ស៊ីស	អ័រដោនេ	ល.រ	អាប់ស៊ីស	អ័រដោនេ
1	483990.079	1287634.536	19	483877.463	1287603.499
2	483974.797	1287623.093	20	483902.026	1287617.264
3	483964.009	1287615.015	21	483913.744	1287623.641
4	483956.453	1287609.357	22	483929.528	1287632.760
5	483948.341	1287603.283	23	483937.980	1287638.177
6	483932.890	1287591.713	24	483946.678	1287624.607
7	483921.308	1287583.040	25	483954.683	1287629.931
8	483900.179	1287567.219	26	483965.868	1287637.371
9	483884.235	1287555.280	27	483981.653	1287647.869
10	483854.271	1287532.843	28	483989.381	1287653.009
11	483802.257	1287493.895	29	484012.711	1287668.525
12	483789.927	1287484.676	30	484027.587	1287678.419
13	483766.864	1287521.154	31	484036.330	1287684.235
14	483776.711	1287528.257	32	484042.919	1287674.102
15	483776.768	1287528.299	33	484034.652	1287667.912
16	483825.664	1287571.595	34	484020.219	1287657.105
17	483862.272	1287593.079	35	483997.755	1287640.284
18	483862.341	1287593.120			

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៤៩ អនក្រ.បក

អនុក្រឹត្យ
ស្ដីពី
ការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២២/០១២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២ ស្ដីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូក នៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣
- បានឃើញអនុក្រឹត្យលេខ ៩៣ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣ ស្ដីពីការផ្ទេរឥណទានថវិកា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា១.-

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ក្នុងជំពូក២១ (គម្រោងវិនិយោគផ្ទាល់) **ចំនួន ៥០១ ០៩០ លានរៀល** ពីខ្ទង់ឥណទានថវិកាមិនទាន់បែងចែកអចលកម្មរូបី ជូនក្រសួងចំនួន ៧ ដូចខាងក្រោម÷

- ក្រសួងសុខាភិបាល ចំនួន ៣ ៥៨០ លានរៀល
- ក្រសួងអប់រំ យុវជន និងកីឡា ចំនួន ១១ ០០០ លានរៀល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន ៨ ១៣០ លានរៀល

- ក្រសួងអភិវឌ្ឍន៍ជនបទ ចំនួន ៨០ ០០០ លានរៀល
- ក្រសួងសាធារណការនិងដឹកជញ្ជូន ចំនួន ១៤៩ ០០០ លានរៀល
- ក្រសួងធនធានទឹកនិងឧតុនិយម ចំនួន ២៣ ៤៨០ លានរៀល
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ២២៥ ៩០០ លានរៀល។

មាត្រា២.-

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកទាំងនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំ[illegible] ព.ស ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ[illegible] ឆ្នាំ២០២៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:២៣០..អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០២៤

រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៥/៣៥៤ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ទៅជា គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

-យោងអនុក្រឹត្យលេខ ១៦៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ របស់រាជរដ្ឋាភិបាល ស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០២៣

-បានឃើញ អនុក្រឹត្យលេខ ២១អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការកំណត់រយៈពេលបម្រើការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា

-បានឃើញ អនុក្រឹត្យលេខ ២៥អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

-តាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

សម្រេច

មាត្រា ១.-

ត្រូវបានអនុញ្ញាតឱ្យមន្ត្រីរាជការ និយោជិត កម្មករ នៃព្រះរាជាណាចក្រកម្ពុជា បានឈប់សម្រាកការងារឆ្នាំ២០២៤ តាមប្រតិទិន ដូចខាងក្រោម ៖

-ថ្ងៃទី ០១	មករា	ទិវាចូលឆ្នាំសកល	សម្រាក០១ថ្ងៃ
-ថ្ងៃទី ០៧	មករា	ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍	សម្រាក០១ថ្ងៃ
-ថ្ងៃទី ០៨	មីនា	ទិវាអន្តរជាតិនារី	សម្រាក០១ថ្ងៃ

-ថ្ងៃទី ១៣-១៤-១៥-១៦	មេសា	ពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំរោង ឆស័ក	សម្រាក០៤ថ្ងៃ
-ថ្ងៃទី ០១	ឧសភា	ទិវាពលកម្មអន្តរជាតិ	សម្រាក០១ថ្ងៃ
-ថ្ងៃទី ១៤	ឧសភា	ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា	សម្រាក០១ថ្ងៃ
-ថ្ងៃទី ២២	ឧសភា	ពិធីបុណ្យវិសាខបូជា	សម្រាក០១ថ្ងៃ
-ថ្ងៃទី ២៦	ឧសភា	ព្រះរាជពិធីច្រត់ព្រះនង្គ័ល	សម្រាក០១ថ្ងៃ
-ថ្ងៃទី ១៨	មិថុនា	ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ**	សម្រាក០១ថ្ងៃ
-ថ្ងៃទី ២៤	កញ្ញា	ទិវាប្រកាសរដ្ឋធម្មនុញ្ញ	សម្រាក០១ថ្ងៃ
-ថ្ងៃទី ០១-០២-០៣	តុលា	ពិធីបុណ្យភ្ជុំបិណ្ឌ	សម្រាក០៣ថ្ងៃ
-ថ្ងៃទី ១៥	តុលា	ទិវាប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទ សម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យបូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"**	សម្រាក០១ថ្ងៃ
-ថ្ងៃទី ២៩	តុលា	ព្រះរាជពិធីគ្រងព្រះបរមរាជសម្បត្តិរបស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា	សម្រាក០១ថ្ងៃ
-ថ្ងៃទី ០៩	វិច្ឆិកា	ពិធីបុណ្យឯករាជ្យជាតិ	សម្រាក០១ថ្ងៃ
-ថ្ងៃទី ១៤-១៥-១៦	វិច្ឆិកា	ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក	សម្រាក០៣ថ្ងៃ

មាត្រា ២.-

ចំពោះក្រសួង ស្ថាប័ន មានភារកិច្ចទំនាក់ទំនងអន្តរជាតិ ត្រូវរក្សាមន្ត្រីប្រចាំការជាអចិន្ត្រៃយ៍ សម្រាប់ដោះស្រាយការងារ។

មាត្រា ៣.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន អភិបាល នៃគណៈអភិបាលរាជធានី និងខេត្ត ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៦ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៧ ខែសីហា ឆ្នាំ២០២៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៣១ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការផ្ទេរដី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៧ ស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- យោងលិខិតលេខ ១៨២ លស ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០២៣ របស់ក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ត្រូវបានផ្ទេរទីតាំងដី ២ ៦៩៤(ពីរពាន់ប្រាំមួយរយកៅសិបបួន) ម៉ែត្រការ៉េ រួមទាំងអគារចំនួន ០៣ ខ្នង ទំហំ ៨០០(ប្រាំបីរយ) ម៉ែត្រការ៉េ(បឹងហ្គាឡូខេត្ត) ស្ថិតនៅភូមិក្រចេះ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ កាត់ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលខេត្តក្រចេះ ទៅឱ្យអង្គភាពប្រឆាំងអំពើពុករលួយ។

មាត្រា២.-

លុបទំហំដី និងអគារ ដូចមានចែងក្នុងមាត្រា១ ខាងលើ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលខេត្តក្រចេះ ហើយត្រូវកត់ត្រាចូលក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពប្រឆាំងអំពើពុករលួយ។

មាត្រា៣.-

ផ្ទៃដី និងចំនួនអគារ ដែលបានផ្ទេរដូចមានកំណត់ក្នុងមាត្រា១ ខាងលើ ត្រូវបានចាត់នីតិវិធីបន្តដោយរដ្ឋបាលខេត្តក្រចេះ និងអង្គភាពប្រឆាំងអំពើពុករលួយ ដែលជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងការលុបចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលខេត្តក្រចេះ និងកត់ត្រាចូលក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពប្រឆាំងអំពើពុករលួយ ស្របតាមនីតិវិធីជាធរមាន។

មាត្រា៤.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង-ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៦ រោច ខែទុតិយាសាឍឆ្នាំ ថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០២៣ ✓

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ២៣៣២ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការផ្ទេរដី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/១៤៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៧ ស្ដីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- យោងលិខិតលេខ ០៧១៤/២៣ ក.អ.ជ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ។

សម្រេច

មាត្រា១._

ត្រូវបានផ្ទេរផ្ទៃដីទំហំ ២៥ ០០០ម^{២} (ម្ភៃប្រាំពាន់ម៉ែត្រការ៉េ) របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តតាកែវ (ក្នុងបរិវេណមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ) ស្ថិតនៅភូមិតាខ្វ សង្កាត់រការក្រៅ ក្រុងដូនកែវ ខេត្តតាកែវ ជូនកងរាជអាវុធហត្ថខេត្តតាកែវ (ដូចមានក្នុងគំនូសប្លង់បង្ហាញទីតាំងភ្ជាប់ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ)។

មាត្រា២._

ផ្ទៃដីដែលបានផ្ទេរដូចមានកំណត់ក្នុងមាត្រា១ នេះ ត្រូវចាត់នីតិវិធីបន្តដោយក្រសួងអភិវឌ្ឍន៍ជនបទជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋព្រមទាំងសហការជាមួយរដ្ឋបាលខេត្តតាកែវ និងអាជ្ញាធរដែនដីពាក់ព័ន្ធ ក្នុងការផ្ទេរការកាន់កាប់ និងកាត់ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តតាកែវ ដើម្បីប្រគល់ទៅឱ្យកងរាជអាវុធហត្ថតាកែវកាន់កាប់ និងចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋវិញ។

មាត្រា៣._

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា៤._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តតាកែវ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៦ រោច ខែទុតិយាសាឍ ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០២៣ ✓

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល÷
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តតាកែវ

ផែនទីឧបសម្ព័ន្ធ: បង្ហាញចំណែកដីស្នើសុំកាត់ចេញពីក្បាលដីលេខ ២១០៨០៣១៤-០៦៧៣ ចំណែក ២៥០០០ម៉ែ
ស្ថិតនៅភូមិត្រពាំងអង្គ សង្កាត់រការក្រៅ ក្រុងដូនកែវ ខេត្តតាកែវ



ID	X	Y
1	474648.062	1212658.480
2	474581.780	1212631.402
3	474563.612	1212625.909
4	474520.142	1212626.654
5	474495.914	1212736.859
6	474489.766	1212782.445
7	474490.869	1212803.936
8	474503.816	1212838.102
9	474522.494	1212878.383
10	474547.454	1212890.904

លេខ : ៣០៤ និងណភ.តក.

បានឃើញ និងឯកភាព
ថ្ងៃ.................... ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
.... ថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០២៣
ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តតាកែវ

ឈួន សុធា

បានឃើញ និងពិនិត្យត្រឹមត្រូវ
សូមគោរពជូន លោកប្រធានមន្ទីរ មេត្តាពិនិត្យ និងសម្រេច ។
ថ្ងៃព្រហស្បតិ៍ ១១ រោច ខែអាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
តាកែវ ថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០២៣
ប្រធានការិយាល័យសុរិយោដី និងភូមិសាស្ត្រ

វ៉ែម_លេខ

ថ្ងៃព្រហស្បតិ៍ ១១ រោច ខែអាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
តាកែវ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៣
វាស់វែង និងរៀបចំផែនទីដោយ:

សុខ សុផាត សុខ រក្សា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៣៣.អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុប្បយោគប្តូរចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- លិខិតលេខ ១៤០៦ សជណ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សម្រេច

មាត្រា១._

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៤២៦,៨៥ (បួនរយម្ភៃប្រាំមួយ ក្បៀសប៉ែតសិបប្រាំ) ហិកតា ដែលមានទីតាំងស្ថិតនៅឃុំហោងសំណំ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ពីដីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាដីទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បីធ្វើការអភិវឌ្ឍវិស័យដំណាំកសិ-ឧស្សាហកម្មចម្រុះ តាមរូបភាពសម្បទានដីសេដ្ឋកិច្ច ដូចមាន ប្លង់ទីតាំងដីរដ្ឋ និងនិយាមកានៃចំណុចព្រំដីចុះបញ្ជីដីរដ្ឋ ទទួលស្គាល់ដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពង់ស្ពឺ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧។

មាត្រា២._

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុង មាត្រា១ នៃអនុក្រឹត្យនេះ ត្រូវស្ថិតនៅក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលខេត្តកំពង់ស្ពឺ ស្របតាមច្បាប់បទប្បញ្ញត្តិពាក់ព័ន្ធ និងគោលការណ៍សម្រេចរបស់រាជរដ្ឋាភិបាល។

មាត្រា៣._

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៤._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវចាត់ចែងអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៦ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០២៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល÷
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៣៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិគាំពារសង្គម

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ចុះថ្ងៃទី២៤ខែកញ្ញាឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១០ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន

- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមការស្នើសុំរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា ១ .-

អនុក្រឹត្យនេះ កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម សរសេរកាត់ថា "គ.ប.ក.គ." និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម សរសេរកាត់ថា "អ.ក.គ." ដើម្បីគាំទ្រដល់ការបំពេញមុខងាររបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ឱ្យប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាពខ្ពស់។

ជំពូកទី២

គណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម

ផ្នែកទី១

សមាសភាព

មាត្រា ២ .-

គ.ប.ក.គ. មានសមាសភាព ដូចខាងក្រោម៖

១-	រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ១ រូប	ប្រធាន
២-	រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ១ រូប	អនុប្រធាន
៣-	រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១ រូប	អនុប្រធាន
៤-	រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការក្រសួងសុខាភិបាល ១ រូប	អនុប្រធាន
៥-	អគ្គលេខាធិការនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ	អនុប្រធាន
៦-	អគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម	អនុប្រធានប្រចាំការ
៧-	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប	សមាជិក
៨-	តំណាងក្រសួងមហាផ្ទៃ ១ រូប	សមាជិក
៩-	តំណាងក្រសួងការពារជាតិ ១ រូប	សមាជិក
១០-	តំណាងក្រសួងផែនការ ១ រូប	សមាជិក
១១-	តំណាងក្រសួងយុត្តិធម៌ ១ រូប	សមាជិក
១២-	តំណាងក្រសួងកិច្ចការនារី ១ រូប	សមាជិក

១៣-	តំណាងក្រសួងអប់រំ យុវជន និងកីឡា ១ រូប	សមាជិក
១៤-	តំណាងក្រសួងមុខងារសាធារណៈ ១ រូប	សមាជិក
១៥-	តំណាងគណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ១ រូប	សមាជិក
១៦-	អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	សមាជិក
១៧-	អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	សមាជិក
១៨-	អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	សមាជិក។

គ.ប.ក.គ. អាចមានសមាសភាពបន្ថែមតាមការចាំបាច់។ សមាសភាពជាក់ស្តែងនៃ **គ.ប.ក.គ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

ជំពូកទី២
តួនាទី និងភារកិច្ច

មាត្រា ៣ .-

គ.ប.ក.គ. ជាយន្តការសម្របសម្រួលកម្រិតគោលនយោបាយ និងកម្រិតបច្ចេកទេស សម្រាប់គាំទ្រលើការបំពេញមុខងារ និងភារកិច្ចរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ដែលមានចែងក្នុងមាត្រា៣នៃព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម។

គ.ប.ក.គ. មានភារកិច្ចសម្របសម្រួល តាមដាន និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រនានាពាក់ព័ន្ធនឹងការងារគាំពារសង្គម ដើម្បីរាយការណ៍ និងផ្តល់យោបល់ជូនក្រុមប្រឹក្សាជាតិគាំពារសង្គម។

គ.ប.ក.គ. អាចស្នើសុំប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម កោះប្រជុំក្រុមប្រឹក្សាជាតិគាំពារសង្គមតាមការចាំបាច់។

មាត្រា ៤ .-

គ.ប.ក.គ. អាចស្នើសុំក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីបង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារបច្ចេកទេសស្របតាមតម្រូវការនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម។

អនុគណៈកម្មាធិការ ក្រុមការងារបច្ចេកទេស និងក្រសួង-ស្ថាប័នពាក់ព័ន្ធដែលមានសកម្មភាព ឬប្រតិបត្តិការគាំពារសង្គម ត្រូវផ្តល់របាយការណ៍អំពីការបំពេញការងាររបស់ខ្លួនជូន **គ.ប.ក.គ.** ជាប្រចាំ។

បែបបទ និងទម្រង់នៃរបាយការណ៍ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។

មាត្រា ៥ .-

គ.ប.ក.គ. មានភារកិច្ចសម្របសម្រួល និងជាសេនាធិការរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីកៀរគរធនធានហិរញ្ញវត្ថុ និងកសាងភាពជាដៃគូលើកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិក្នុងកិច្ចការគាំពារសង្គម។

ផ្នែកទី៣
ការប្រជុំនៃគណៈកម្មាធិការប្រតិបត្តិ

មាត្រា ៦ .-

អនុប្រធាន និងសមាជិកនៃ គ.ប.ក.គ. ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬត្រូវចាត់តំណាងដែលមានសិទ្ធិសម្រេចឱ្យចូលរួមប្រជុំជំនួស ក្នុងករណីអវត្តមាន។

គ.ប.ក.គ. អាចអញ្ជើញប្រធានអនុគណៈកម្មាធិការ ប្រធានក្រុមការងារបច្ចេកទេស ឬតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា តំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន និងតំណាងសង្គមស៊ីវិល ដើម្បីពិភាក្សាការងារក្នុងគោលដៅជំរុញវឌ្ឍនភាពនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម តាមការចាំបាច់។

មាត្រា ៧.-

ប្រធាន គ.ប.ក.គ. ក្នុងនាមជាសេនាធិការដឹកនាំ ត្រូវចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាជាតិគាំពារសង្គមក្នុងនាមជាអ្នកផ្តល់យោបល់។ ក្នុងករណីអវត្តមាន ប្រធាន គ.ប.ក.គ. ត្រូវផ្ទេរសិទ្ធិជូនអនុប្រធានដើម្បីចូលរួមប្រជុំជំនួស។

ជំពូកទី៣
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម

ផ្នែកទី១
ការបង្កើតអគ្គលេខាធិការដ្ឋាន

មាត្រា ៨.-

ត្រូវបានបង្កើតអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ជាសេនាធិការបច្ចេកទេសគាំទ្រការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម និងគណៈកម្មាធិការប្រតិបត្តិ ដូចមានចែងក្នុងមាត្រា ៥ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម។

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម បំពេញមុខងារបន្ថែមជានិយ័តករសន្តិសុខសង្គម ដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

ផ្នែកទី២
រចនាសម្ព័ន្ធ មុខងារ និងភារកិច្ច

មាត្រា ៩.-

អ.ក.គ. មានរចនាសម្ព័ន្ធ មុខងារ និងភារកិច្ច ដូចខាងក្រោម៖

- **នាយកដ្ឋានគោលនយោបាយ** មានមុខងារ និងភារកិច្ច ជួយ អ.ក.គ. លើការងាររៀបចំ ពិនិត្យ និងផ្តល់យោបល់លើគោលនយោបាយគាំពារសង្គមជារួម ការងាររៀបចំបង្កើត និងដាក់ឱ្យដំណើរការរបបសន្តិសុខសង្គម ឬកម្មវិធីជាតិជំនួយសង្គមនានា

- នាយកដ្ឋានគាំទ្រប្រតិបត្តិការ មានមុខងារ និងភារកិច្ច ជួយ អ.ក.គ. លើការងារគ្រប់គ្រងមូលនិធិហិរញ្ញប្បទានគាំពារសង្គម ការងារតាមដាន និងដោះស្រាយវិវាទក្នុងការអនុវត្តកម្មវិធីជាតិជំនួយសង្គម និងការងារបញ្ជ្រាបការយល់ដឹង ទំនាក់ទំនង និងការផ្សព្វផ្សាយ
- នាយកដ្ឋានកិច្ចការរដ្ឋបាល និងឌីជីថល មានមុខងារ និងភារកិច្ច ជួយ អ.ក.គ. លើការងាររដ្ឋបាល និងការគ្រប់គ្រងបុគ្គលិក ការងារគ្រប់គ្រងថវិកាកម្មវិធី និងគម្រោងអភិវឌ្ឍន៍ស្ថាប័ន និងការងារអភិវឌ្ឍ និងអនុវត្តថ្នាលឌីជីថល
- នាយកដ្ឋានត្រួតពិនិត្យ មានមុខងារ និងភារកិច្ច ជួយ អ.ក.គ. ក្នុងមុខងារជានិយ័តករសន្តិសុខសង្គម លើការងាររៀបចំបទប្បញ្ញត្តិពាក់ព័ន្ធនឹងនិយ័តកម្មប្រព័ន្ធសន្តិសុខសង្គម និងការងារត្រួតពិនិត្យប្រតិបត្តិការសន្តិសុខសង្គម
- នាយកដ្ឋានផ្សះផ្សាវិវាទ និងការពារអ្នកទទួលផល មានមុខងារ និងភារកិច្ច ជួយ អ.ក.គ. ក្នុងមុខងារជានិយ័តករសន្តិសុខសង្គម លើការងារការពារអ្នកទទួលផល ការងារទទួលពាក្យបណ្ដឹង និងការងារដោះស្រាយវិវាទ ក្នុងប្រព័ន្ធសន្តិសុខសង្គម
- នាយកដ្ឋានកិច្ចការទូទៅ មានមុខងារ និងភារកិច្ច ជួយ អ.ក.គ. ក្នុងមុខងារជានិយ័តករសន្តិសុខសង្គម លើការងារថវិកា និងការគ្រប់គ្រងបុគ្គលិក ការងារគាំទ្រប្រតិបត្តិការពាក់ព័ន្ធនឹងប្រព័ន្ធព័ត៌មានវិទ្យា និងការងារសម្របសម្រួលក្នុងក្របខណ្ឌអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និង
- អង្គភាពស្រាវជ្រាវ មានមុខងារ និងភារកិច្ច ជួយ អ.ក.គ. លើការងារសិក្សាស្រាវជ្រាវទូទៅ។

អង្គភាព និងនាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធាន ១ រូប និងមានអនុប្រធានមួយចំនួនអនុលោមតាមបទដ្ឋានគតិយុត្តជាធរមាន។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

ការរៀបចំ និង ការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

ផ្នែកទី៣
ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក

មាត្រា ១០. -

អគ្គលេខាធិការដ្ឋាន ត្រូវដឹកនាំដោយអគ្គលេខាធិការ ១ រូប និងមានអគ្គលេខាធិការរងមួយចំនួនអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អគ្គលេខាធិការ ត្រូវបានតែងតាំង និងបញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យ តាមការស្នើសុំរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

មាត្រា ១១. -

អគ្គលេខាធិការរង ត្រូវបានតែងតាំង និងបញ្ចប់ភារកិច្ចដោយអនុក្រឹត្យ តាមការស្នើសុំរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។ អគ្គលេខាធិការរង អាចត្រូវបានតែងតាំងជាអគ្គនាយករងនៃនិយ័តករសន្តិសុខសង្គម តាមការចាំបាច់។

មាត្រា ១២.-

អ.ក.គ. អាចជ្រើសរើសមន្ត្រីរាជការមុខងារសាធារណៈ ពីក្រសួង-ស្ថាប័ននានា និងពីក្នុងចំណោមសិស្ស និស្សិតមកបម្រើការងារនៅ អ.ក.គ. ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្របតាមនីតិវិធីជាធរមាន។

មាត្រា ១៣.-

អ.ក.គ. អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា និងទីប្រឹក្សាជាអ្នកជំនាញការជាតិ ឬអន្តរជាតិ មកបម្រើការងារ ដោយមានការឯកភាពពីប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម អនុលោមតាមបែបបទ និងនីតិវិធីជាធរមាន។

ផ្នែកទី៤
ថវិកា

មាត្រា ១៤. -

អ.ក.គ មានកញ្ចប់ថវិកាដោយឡែកសម្រាប់គាំទ្រកិច្ចដំណើរការរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម **គ.ប.ក.គ** និង **អ.ក.គ** ផ្ទាល់។ កញ្ចប់ថវិការបស់ **អ.ក.គ** អាចមានប្រភពមកពី៖

- ថវិការដ្ឋដែលស្ថិតនៅក្រោមកញ្ចប់ថវិការបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង
- ប្រភពស្របច្បាប់ផ្សេងៗទៀត។

ថវិការបស់ **អ.ក.គ** ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមការស្នើសុំរបស់អគ្គលេខាធិការ តាមរយៈប្រធាន គ.ប.ក.គ។

ផ្នែកទី៥
សវនកម្ម

មាត្រា ១៥. -

អ.ក.គ ត្រូវស្ថិតក្រោមការធ្វើអធិការកិច្ច និងសវនកម្ម ស្របតាមច្បាប់ជាធរមាន។

ជំពូកទី៤
អវសានប្បញ្ញត្តិ

មាត្រា ១៦. -

អនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម និងអនុក្រឹត្យលេខ១៤៣ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ០៣ អនក្រ.បក និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យទាំងពីរនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ១៧. -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៦ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០២៣ ✓

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...២៣៤ អនក្រ.បក...ចុះថ្ងៃទី...១៧.....ខែ...សីហា.....ឆ្នាំ២០២៣

អង្គការលេខរបស់

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម (អ.ក.គ)



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៣៥ អនក្រ.បក

អនុក្រឹត្យ

ស្ដីពី

ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស អិលអិល ប៉ោយប៉ែត

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្ដីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច៤.១ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- យោងតាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

សម្រេច

មាត្រា១.-

ត្រូវបានបង្កើត **តំបន់សេដ្ឋកិច្ចពិសេស អិលអិល ប៉ោយប៉ែត** ដែលមានទីតាំងស្ថិតនៅភូមិសុខសាន្ត សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

មាត្រា២.-

តំបន់សេដ្ឋកិច្ចពិសេស អិលអិល ប៉ោយប៉ែត មានទំហំ ៥៨៤ ២០៩ម^2 (ប្រាំរយប៉ែតសិបបួនពាន់ ពីររយប្រាំបួន ម៉ែត្រការ៉េ) ដូចមានប្លង់បង្ហាញទីតាំងក្បាលដី និងតារាងនិយាមកាចំណុចព្រំដីភ្ជាប់ជាឧបសម្ព័ន្ធ ដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ចជាចំណែកភ្ជាប់អនុក្រឹត្យនេះ។

មាត្រា៣.-

ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេស អិលអិល ប៉ោយប៉ែត** ដូចមានកំណត់ក្នុងមាត្រា២ ជាកម្មសិទ្ធិឯកជនស្របច្បាប់របស់ក្រុមហ៊ុន សម្រាប់ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស។

មាត្រា៤.-

ការរៀបចំ និងការប្រព្រឹត្តទៅនៃ **តំបន់សេដ្ឋកិច្ចពិសេស អិលអិល ប៉ោយប៉ែត** នេះ នឹងស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទប្បញ្ញត្តិនានានៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធទាំងអស់ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ៧ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែសីហា ឆ្នាំ២០២៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីសូមចុះហត្ថលេខា

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

សុខ ចិន្តាសោភា

កន្លែងទទួល÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រធាន ក.អ.ក
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- ក្រុមហ៊ុន អិលអិល ប៉ោយប៉ែត ស្ពេសល អ៊ីឃើណូមិក ហ្សូន ឯ.ក
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៣៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកែសម្រួលផ្ទៃប្រព័ន្ធបឹងវាលសំណាបទំហំ ៤ ៨១៥ ហិកតា ស្ថិតក្នុងខេត្តកណ្តាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២២/១២៣៦ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកំណត់ផ្ទៃប្រព័ន្ធបឹងវាលសំណាប ទំហំ ៤ ៨១៥ ហិកតា ស្ថិតក្នុងខេត្តកណ្តាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ
- យោងតាមសំណើរបស់រដ្ឋបាលខេត្តកណ្តាល

សម្រេច

មាត្រា១ .-

ត្រូវបានកាត់ផ្ទៃដីទំហំ ៤៧១ ហិកតា ២៦ អា ៤១ សង់ទីអា ស្ថិតនៅភូមិខ្មោរកា និងភូមិបារុង សង្កាត់បារុង ក្រុងអរិយក្សត្រ ខេត្តកណ្តាល ដែលបានកំណត់ក្នុងអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ

ឆ្នាំ២០១៦ ស្តីពីការកំណត់ផ្ទៃប្រព័ន្ធបឹងវាលសំណាប ទំហំ ៤ ៨១៥ ហិកតា ស្ថិតក្នុងខេត្តកណ្តាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទី និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ធ្វើប្រទានកម្ម និងចុះបញ្ជីជូនក្រុមហ៊ុន 3អិលអិមធី អ៊ិនវេសម៉ិន ឯ.ក។

មាត្រា២ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកណ្តាល ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៧រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ២០២៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

អន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ


ផែនទីប្លង់បង្ហាញទីតាំងស្នើសុំប្រទានកម្ម ទំហំ ៤៧១ហិកតា ២៦៤១ម៉ែត្រការ៉េ
504000
506000
510000
1285000
1282000
1279000
សម្គាល់
ដីស្នើសុំប្រទានកម្មមានទំហំ ៤៧១ហិកតា ២៦៤១ម៉ែត្រការ៉េ


ផែនទីប្លង់បង្ហាញទីតាំងសំណើសុំប្រទានកម្ម ទំហំ ៤៧១ហិកតា ២៦៤១ម៉ែត្រការ៉េ
504000
506000
508000
510000
1285000
1282000
1279000
សម្គាល់
ដីអនុក្រឹត្យរក្សាទុក ទទឹង ១០០ម៉ែត្រមានទំហំ ៣០៥ហិកតា ៤២៤៥ម៉ែត្រការ៉េ
ដីស្នើសុំប្រទានកម្មមានទំហំ ៤៧១ហិកតា ២៦៤១ម៉ែត្រការ៉េ
ដីជីកស្តាររក្សាទុកផ្ទៃទឹកមានទំហំ ៣២៨ហិកតា ២៨១៤ម៉ែត្រការ៉េ
ផ្លូវត្រូវស្ថាបនាថ្មី ប្រវែង ១១៩៣៨ម៉ែត្រ មានទំហំ ៣១ហិកតា ៣៤៩៨ម៉ែត្រការ៉េ



ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ.២៣៦.......អនក្រ.បក ចុះថ្ងៃទី....៨........ខែ..សីហា......ឆ្នាំ២០២៣

ស្ដីពីការកែសម្រួលផ្ទៃប្រព័ន្ធបឹងខាលសំណាប ទំហំ ៤ ៨១៥ ហិកតា ស្ថិតក្នុងខេត្តកណ្ដាល

ជាសម្បត្តិសាធារណៈរបស់រដ្ឋ

ល.រ	អាប់ស៊ីស	អ័រដោនេ	ល.រ	អាប់ស៊ីស	អ័រដោនេ
១	507120.019	1286312.225	៤៤២	508172.397	1284212.227
២	507070.741	1286390.935	៤៤៣	508190.133	1284246.466
៣	506997.491	1286507.935	៤៤៤	508208.668	1284280.281
៤	506943.809	1286593.680	៤៤៥	508227.990	1284313.652
៥	506930.132	1286547.017	៤៤៦	508251.023	1284352.028
៦	506917.184	1286500.146	៤៤៧	508268.299	1284393.316
៧	506904.968	1286453.079	៤៤៨	508279.461	1284436.659
៨	506893.487	1286405.828	៤៤៩	508284.277	1284481.157
៩	506882.744	1286358.403	៤៥០	508282.646	1284525.884
១០	506872.741	1286310.817	៤៥១	508274.602	1284569.913
១១	506863.481	1286263.080	៤៥២	508260.312	1284612.328
១២	506854.966	1286215.205	៤៥៣	508240.074	1284652.248
១៣	506847.199	1286167.204	៤៥៤	508236.461	1284674.040
១៤	506840.181	1286119.086	៤៥៥	508248.746	1284692.398
១៥	506833.913	1286070.866	៤៥៦	508166.783	1284673.344
១៦	506828.398	1286022.553	៤៥៧	508191.907	1284662.310
១៧	506823.636	1285974.161	៤៥៨	508210.859	1284642.465
១៨	506819.629	1285925.700	៤៥៩	508230.390	1284605.958
១៩	506816.378	1285877.182	៤៦០	508244.335	1284566.974
២០	506813.884	1285828.620	៤៦១	508252.391	1284526.362
២១	506812.147	1285780.025	៤៦២	508254.381	1284485.006
២២	506811.167	1285731.409	៤៦៣	508250.264	1284443.808
២៣	506810.945	1285682.783	៤៦៤	508240.127	1284403.665
២៤	506811.481	1285634.159	៤៦៥	508224.193	1284365.451
២៥	506812.775	1285585.550	៤៦៦	508202.808	1284329.998
២៦	506814.827	1285536.967	៤៦៧	508183.103	1284296.021
២៧	506817.635	1285488.422	៤៦៨	508164.200	1284261.591

២៨	506821.199	1285439.927	៤៦៩	508146.110	1284226.727
២៩	506825.519	1285391.493	៤៧០	508128.843	1284191.449
៣០	506830.594	1285343.132	៤៧១	508112.409	1284155.774
៣១	506836.421	1285294.856	៤៧២	508096.815	1284119.725
៣២	506839.698	1285291.348	៤៧៣	508082.072	1284083.319
៣៣	506868.038	1285455.504	៤៧៤	508068.187	1284046.577
៣៤	507043.854	1285524.529	៤៧៥	508055.168	1284009.520
៣៥	507059.110	1285682.077	៤៧៦	508043.021	1283972.168
៣៦	507074.337	1285839.614	៤៧៧	508031.754	1283934.541
៣៧	507081.951	1285918.382	៤៧៨	508021.373	1283896.660
៣៨	507089.564	1285997.151	៤៧៩	508011.884	1283858.546
៣៩	507104.792	1286154.688	៤៨០	508003.291	1283820.220
៤០	507120.019	1286312.225	៤៨១	507995.599	1283781.702
៤១	508682.822	1285143.566	៤៨២	507988.814	1283743.015
៤២	508688.706	1285191.473	៤៨៣	507982.937	1283704.180
៤៣	508623.879	1285194.798	៤៨៤	507977.974	1283665.217
៤៤	508341.030	1285209.303	៤៨៥	507969.697	1283625.973
៤៥	507674.676	1285325.386	៤៨៦	507959.050	1283587.306
៤៦	507672.005	1285604.543	៤៨៧	507946.071	1283549.357
៤៧	507670.789	1285731.552	៤៨៨	507930.808	1283512.268
៤៨	507726.906	1285852.871	៤៨៩	507913.318	1283476.176
៤៩	507773.573	1285953.760	៤៩០	507893.667	1283441.214
៥០	507820.239	1286054.648	៤៩១	507871.925	1283407.511
៥១	507866.906	1286155.538	៤៩២	507848.175	1283375.193
៥២	507913.573	1286256.426	៤៩៣	507822.503	1283344.379
៥៣	507960.239	1286357.315	៤៩៤	507790.192	1283309.706
៥៤	507966.306	1286370.431	៤៩៥	507757.122	1283275.757
៥៥	507893.486	1286281.742	៤៩៦	507723.310	1283242.547
៥៦	507810.886	1286181.142	៤៩៧	507688.771	1283210.092
៥៧	507690.667	1286034.726	៤៩៨	507653.523	1283178.409
៥៨	507516.085	1286067.742	៤៩៩	507617.584	1283147.514
៥៩	507399.752	1286089.742	៥០០	507580.970	1283117.420

៦០	507240.448	1286119.868	៥០១	507548.694	1283096.436
៦១	507164.138	1286241.754	៥០២	507512.880	1283082.312
៦២	507129.935	1285887.899	៥០៣	507474.968	1283075.618
៦៣	507169.669	1285823.723	៥០៤	507436.483	1283076.621
៦៤	507195.990	1285781.211	៥០៥	507396.874	1283083.265
៦៥	507222.310	1285738.700	៥០៦	507357.918	1283093.031
៦៦	507248.631	1285696.188	៥០៧	507319.859	1283105.855
៦៧	507274.952	1285653.677	៥០៨	507282.937	1283121.659
៦៨	507301.272	1285611.165	៥០៩	507271.384	1283132.336
៦៩	507327.593	1285568.654	៥១០	507267.242	1283147.512
៧០	507353.914	1285526.142	៥១១	507271.769	1283162.578
៧១	507380.234	1285483.631	៥១២	507283.590	1283172.957
៧២	507406.555	1285441.119	៥១៣	507323.552	1283189.162
៧៣	507432.777	1285398.768	៥១៤	507362.435	1283207.808
៧៤	507460.287	1285357.862	៥១៥	507400.091	1283228.824
៧៥	507491.528	1285320.101	៥១៦	507436.374	1283252.129
៧៦	507526.437	1285285.230	៥១៧	507471.146	1283277.633
៧៧	507562.813	1285251.300	៥១៨	507504.274	1283305.239
៧៨	507599.822	1285217.932	៥១៩	507535.631	1283334.841
៧៩	507637.389	1285185.194	៥២០	507565.097	1283366.327
៨០	507675.504	1285153.095	៥២១	507592.559	1283399.574
៨១	507714.156	1285121.645	៥២២	507617.912	1283434.457
៨២	507753.334	1285090.853	៥២៣	507642.570	1283476.854
៨៣	507793.027	1285060.728	៥២៤	507664.856	1283520.544
៨៤	507833.155	1285031.328	៥២៥	507684.703	1283565.394
៨៥	507874.002	1285003.476	៥២៦	507702.051	1283611.270
៨៦	507916.802	1284978.782	៥២៧	507716.847	1283658.030
៨៧	507960.703	1284955.757	៥២៨	507729.045	1283705.535
៨៨	508005.557	1284934.717	៥២៩	507738.610	1283753.639
៨៩	508051.320	1284915.746	៥៣០	507745.512	1283802.197
៩០	508097.900	1284898.879	៥៣១	507749.730	1283851.061
៩១	508145.201	1284884.154	៥៣២	507751.252	1283900.083

៩២	508193.126	1284871.598	៥៣៣	507753.480	1283940.785
៩៣	508241.564	1284861.223	៥៣៤	507757.248	1283981.374
៩៤	508290.435	1284853.102	៥៣៥	507762.548	1284021.792
៩៥	508339.624	1284847.199	៥៣៦	507769.374	1284061.979
៩៦	508389.031	1284843.576	៥៣៧	507777.716	1284101.880
៩៧	508438.554	1284842.213	៥៣៨	507787.562	1284141.437
៩៨	508488.088	1284843.108	៥៣៩	507798.897	1284180.592
៩៩	508537.528	1284846.260	៥៤០	507811.707	1284219.291
១០០	508586.773	1284851.662	៥៤១	507825.971	1284257.477
១០១	508651.217	1284861.722	៥៤២	507841.671	1284295.096
១០២	508654.466	1284892.940	៥៤៣	507858.782	1284332.094
១០៣	508659.818	1284943.094	៥៤៤	507877.282	1284368.418
១០៤	508665.330	1284993.239	៥៤៥	507897.142	1284404.016
១០៥	508671.001	1285043.367	៥៤៦	507918.336	1284438.837
១០៦	508676.832	1285093.476	៥៤៧	507940.832	1284472.830
១០៧	508682.822	1285143.566	៥៤៨	507964.599	1284505.949
១០៨	506997.284	1283123.659	៥៤៩	507989.601	1284538.144
១០៩	507030.730	1283134.851	៥៥០	508015.804	1284569.370
១១០	507065.368	1283141.495	៥៥១	508043.170	1284599.582
១១១	507100.582	1283143.474	៥៥២	508071.660	1284628.737
១១២	507144.359	1283136.948	៥៥៣	508091.672	1284647.558
១១៣	507187.388	1283126.577	៥៥៤	508113.817	1284663.816
១១៤	507229.331	1283112.444	៥៥៥	508139.348	1284673.873
១១៥	507269.861	1283094.658	៥៥៦	508166.783	1284673.344
១១៦	507306.086	1283079.012	៥៥៧	508427.916	1282910.500
១១៧	507343.364	1283066.075	៥៥៨	508448.626	1282956.457
១១៨	507381.492	1283055.916	៥៥៩	508468.960	1283002.582
១១៩	507420.265	1283048.590	៥៦០	508488.917	1283048.872
១២០	507459.472	1283044.137	៥៦១	508508.494	1283095.323
១២១	507498.900	1283042.581	៥៦២	508527.691	1283141.932
១២២	507538.335	1283043.931	៥៦៣	508546.506	1283188.697
១២៣	507577.565	1283048.179	៥៦៤	508564.939	1283235.615

១២៤	507616.375	1283055.302	៥៦៥	508582.987	1283282.681
១២៥	507665.279	1283066.053	៥៦៦	508600.649	1283329.894
១២៦	507714.225	1283076.612	៥៦៧	508617.925	1283377.249
១២៧	507763.212	1283086.980	៥៦៨	508634.813	1283424.744
១២៨	507809.682	1283100.578	៥៦៩	508651.313	1283472.375
១២៩	507855.118	1283117.311	៥៧០	508667.422	1283520.140
១៣០	507899.307	1283137.102	៥៧១	508683.140	1283568.035
១៣១	507942.045	1283159.859	៥៧២	508698.466	1283616.056
១៣២	507981.822	1283184.912	៥៧៣	508713.399	1283664.202
១៣៣	508019.545	1283212.964	៥៧៤	508727.938	1283712.468
១៣៤	508054.988	1283243.846	៥៧៥	508742.082	1283760.851
១៣៥	508087.938	1283277.374	៥៧៦	508755.830	1283809.348
១៣៦	508113.839	1283308.225	៥៧៧	508769.180	1283857.956
១៣៧	508137.214	1283341.032	៥៧៨	508782.133	1283906.672
១៣៨	508157.916	1283375.588	៥៧៩	508794.687	1283955.491
១៣៩	508175.815	1283411.675	៥៨០	508806.842	1284004.412
១៤០	508190.799	1283449.067	៥៨១	508818.596	1284053.431
១៤១	508202.772	1283487.529	៥៨២	508829.949	1284102.544
១៤២	508211.661	1283526.818	៥៨៣	508840.900	1284151.748
១៤៣	508217.408	1283566.688	៥៨៤	508851.448	1284201.040
១៤៤	508219.979	1283606.888	៥៨៥	508861.593	1284250.417
១៤៥	508219.356	1283647.166	៥៨៦	508871.334	1284299.875
១៤៦	508218.465	1283696.796	៥៨៧	508880.670	1284349.411
១៤៧	508221.261	1283746.355	៥៨៨	508889.601	1284399.021
